# ព្រះរាជក្រឹត្យ

នស/រកត/១០១៣/១០៦៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងផែនការ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨០៤/០០១ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៤ ស្តីពីការបង្កើតគណៈកម្មាធិការជាតិ ប្រជាជន និងការអភិវឌ្ឍ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១.-**

ត្រូវបានផ្ទេរគណៈកម្មាធិការជាតិ ប្រជាជន និងការអភិវឌ្ឍ ដែលត្រូវបានបង្កើតដោយព្រះរាជក្រឹត្យលេខ នស/រកត/០៨០៤/០០១ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៤ ដោយធ្វើសមាហរណកម្មការងារ និងរចនាសម្ព័ន្ធទាំងឡាយ រួមមាន ថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិក ចលនទ្រព្យ អចលនទ្រព្យ ។ល។ របស់គណៈកម្មាធិការជាតិនេះ ដែលមានកន្លងមក ឲ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងផែនការ វិញ ។

**មាត្រា ២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣.-**

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រស. ១៣១០.១០៧៥

លេខ: ១០៧៥ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ១០ ឆ្នាំ២០១៣
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៣*

**សយ សុខា**